01082145

F2/4/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Apr-2015, 14:57
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier Nº. 002/19-09-2007-ECCC/SC

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រីម ជាប្រធាន |
| | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម Agnieszka KLONOWIECKA-MILART |
| | ចៅក្រម ម៉ុង មុនីចរិយា |
| | ចៅក្រម Florence Ndepele MWACHANDE-MUMBA |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ |
| ភាសា៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឲ្យទទួល និង ពិចារណានៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE

**សហមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល"សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ដែលបានដាក់ដោយ នួន ជា នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ ("សំណើ")[1]។ ខៀវ សំផន បានចូលរួមក្នុងសំណើនោះនៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤[2]។ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួនទៅនឹងសំណើនេះ ("សារណាតប")[3] ដែល នួន ជា បានឆ្លើយតបវិញនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤ ("ការឆ្លើយតប")[4]។

## ក. សាវតា

២. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ("សាលក្រម")[5] ដោយរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (រួមទាំងបទការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដោយរួមទាំងការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ) និងបានផ្តន្ទាទោសដាក់ពន្ធនាគារពួកគេអស់មួយជីវិត[6]។ ការដាក់ពិរុទ្ធភាពទាំងនេះ ផ្អែកទៅលើបទចោទនានានៅក្នុងដីកាដំណោះស្រាយ

---

[1] ឯកសារលេខ F2។

[2] *មតិគាំទ្ររបស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះសំណើពីរដំបូងរបស់មេធាវីការពារក្តីលោក នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ (F2 និង F2/1)* ឯកសារ F2/1/1 ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[3] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីររបស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/2 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ (ត្រូវបានជូនដំណឹងនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤។ ត្រូវបានជូនដំណឹងម្តងទៀត នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយសារកំហុសបច្ចេកទេស)។

[4] ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/3 ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤។

[5] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

[6] សាលក្រមសាលាដំបូង ទំព័រ ៩៩៦។

ដែលទាក់ទិននឹងតួនាទី និងមុខងាររបស់ ខៀវ សំផន និង នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា (“ប.ក.ក”) និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ពួកគេ ទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) រួមទាំងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[7]។

៣. ជាមួយនឹងសំណើ នួន ជា ស្នើសុំ*ក្នុងចំណោមនោះ*ដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យទទួលយកសម្ភារៈដែលពាក់ព័ន្ធ និងដែលជាកម្មសិទ្ធិរបស់ ថេត សម្បត្តិ និង Robert LEMKIN ដោយយល់ឃើញថាគួរបញ្ចូលសម្ភារៈនេះទៅក្នុងភស្តុតាងនៃបណ្តឹងសាទុក្ខ ដែល នួន ជា លើកឡើងថា ជាការដោះបន្ទុក និងអាចជាកត្តាកំណត់សំខាន់ក្នុងសេចក្តីសម្រេចមួយចំនួនដែលបានធ្វើឡើងក្នុងដំណាក់កាលជំនុំជម្រះក្តី[8]។

៤. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង (“សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ”)[9]។ បន្ទាប់មកពួកគេបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[10]។

## ខ. **សារណា**

៥. សំណើសុំការទទួលយកជាភស្តុតាងនូវខ្សែអាត់ថតសំឡេងនៃកិច្ចសម្ភាសន៍មួយនៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ដែល ថេត សម្បត្តិ បានផ្តល់ជាមួយវិទ្យុវីអូអេភាសាខ្មែរ (“កិច្ចសម្ភាសន៍”)[11]។ ជាងនេះទៀត នួន ជា បានស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលមេត្តាកោះហៅ ថេត សម្បត្តិ និង Robert LEMKIN ដែលជាសហប្រធាន និងជាសហផលិតករនៃខ្សែភាពយន្តចំនួនពីរ ដែលមាននៅក្នុង

---

[7] *សូមមើល* សាលក្រមសាលាដំបូង កថាខណ្ឌ ១១, ១៦៨, ៤១០, ៤១៤, ៤២៥, ៤៣៤, ៤៤១, ៤៤៩, ៤៥៦, ៤៥៩, ៥៧៥, ៦៥៨ ដល់ ៦៥៩, ៧២៣, ៨៣៨, ៩៤៣។

[8] សំណើ កថាខណ្ឌ ១, ៦, ១៣ ដល់ ១៨។ *សូមមើលផងដែរ* ការឆ្លើយតប កថាខណ្ឌ ១។ សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣។

[9] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១* ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[10] *សូមមើល* បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ F16 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (“សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា”)។ *[Corrigé 1] Mémoire d’appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01* ឯកសារ F17 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (សំណៅដែលបានកែប្រែត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។

[11] សំណើ កថាខណ្ឌ ៦, ១៨(ក)។

សំណុំរឿង គឺរឿង *សត្រូវប្រជាជន* និង *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* ដើម្បីមកផ្តល់សក្ខីកម្មអំពីឈុតខ្សែវីដេអូ ដែលត្រូវបានថត សម្រាប់ជាគោលបំណងរបស់ខ្សែភាពយន្តទាំងនោះ និងត្រូវបាននិយាយយោងនៅក្នុងកិច្ចសម្ភាសន៍ ("ឈុតខ្សែវីដេអូ") ហើយថា អង្គជំនុំជម្រះ គួរចាត់ការភ្លាមៗដើម្បីទទួលយកឈុតខ្សែវីដេអូ[12]។ នួន ជា បានលើកឡើងថា កិច្ចសម្ភាសន៍សក្ខីកម្មរបស់សាក្សីដែលខ្លួនបានស្នើឡើង និងឈុតខ្សែវីដេអូនោះ គឺជាការដោះបន្ទុក និងអាចជាកត្តាកំណត់សំខាន់ក្នុងសេចក្តីសម្រេចមួយចំនួនដែលបានធ្វើឡើងក្នុងដំណាក់កាលជំនុំជម្រះក្តី[13]។

៦. អនុលោមតាមប្រតិចារិកនៃកិច្ចសម្ភាសន៍ដែលបានផ្តល់ដោយមេធាវីការពារក្តី នួន ជា និងបានបញ្ចូលក្នុងសំណើ ថេត សម្បត្តិ បានរិះគន់សាលក្រមផ្តន្ទាទោស នួន ជា ដោយបាននិយាយថា ការស្រាវជ្រាវរបស់គាត់គាំទ្រដល់ការសន្និដ្ឋានថា ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែល នួន ជា ត្រូវបានរកឃើញថាមានពិរុទ្ធភាព គឺជាការទទួលខុសត្រូវចម្បងរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ដែលពួកគេភាគច្រើនជាសមាជិករដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ហើយដោយមូលហេតុទាំងនេះ ទើបសាក្សីសក្តានុពល មានការរារែកមិនចង់មកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ដោយសារពួកគេយល់ថា តុលាការនេះ ពុំមានឯករាជភាព និងភាពគ្មានអនាគតិ[14]។ នួន ជា លើកជាទឡ្ហីករណ៍ថា ហេតុនេះ កិច្ចសម្ភាសន៍បង្ហាញភស្តុតាងថា ដោយសារមានការជ្រៀតជ្រែករបស់រដ្ឋាភិបាល ភស្តុតាងដោះបន្ទុកគន្លឹះនានា មិនត្រូវបានបញ្ចូលក្នុងកំណត់ហេតុ ដែលបានប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការការពារក្តីរបស់ខ្លួន[15]។

៧. នួន ជា លើកឡើងថា បទសម្ភាសន៍នេះអាចនឹងជាកត្តាក្នុងការធ្វើសេចក្តីសម្រេច ទាក់ទងទៅនឹង (១) ការយល់ឃើញជាច្រើន នៅក្នុងសាលក្រម និង (២)សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣"[16]។ ទីមួយ បទសម្ភាសន៍ និងភស្តុតាងដែលត្រូវបានយោងនៅទីនោះ ត្រូវបានគេជឿថា នាំឲ្យមានសំណួរដល់សុពលភាពនៃសេចក្តីសន្និដ្ឋានរបស់សាលក្រម ពាក់ព័ន្ធទៅនឹងឋានានុក្រមនៃរចនាសម្ព័ន្ធ ប.ក.ក ការពឹងផ្អែក

---

[12] សំណើ កថាខណ្ឌ ១៧, ១៨(ខ)។

[13] សំណើ កថាខណ្ឌ ១, ៦, ១៣ ដល់ ១៨។ *សូមមើលផងដែរ* ការឆ្លើយតប កថាខណ្ឌ ១។ សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣។

[14] សំណើ ទំព័រ ៥ ដល់ ៩។

[15] សំណើ កថាខណ្ឌ ១៦។ សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧, ៧៤។ *សូមមើលផងដែរ* ការឆ្លើយតប កថាខណ្ឌ ១។

[16] សេចក្តីសម្រេចស្តីពីសំណើរបស់ នួន ជា សុំទទួលយកឯកសារថ្មី ដើម្បីផ្តួចផ្តើមការស៊ើបអង្កេត និងកោះហៅ លោក Mr. Rob LEMKIN, ឯកសារលេខ E294/1, ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣។

របស់កម្មាភិបាលថ្នាក់ក្រោម និងការទទួលខុសត្រូវរបស់ នួន ជា ចំពោះការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ដែលមានភស្តុតាងគាំទ្រ ដោយដកស្រង់ការងាររបស់ ថេត សម្បត្តិ[17]។

៨. ទីពីរ នួន ជា អះអាងថា កិច្ចសម្ភាសន៍អាចជាកត្តាកំណត់មួយសម្រាប់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ដែលបានបដិសេធសំណើរបស់ នួន ជា សុំកោះហៅ Robert LEMKIN ឬបើកកិច្ចស៊ើបសួរបន្ទាប់ពី Robert LEMKIN បានផ្ញើសារអេឡិចត្រូនិកមួយទៅមេធាវីការពារក្តីនៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៤ ដោយចង្អុលបង្ហាញថា គាត់ និង ថេត សម្បត្តិ បានប្រមូលភស្តុតាងថា ឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃមិនត្រូវបានបញ្ជាពីថ្នាក់មជ្ឈិមទេ[18]។ នួន ជា ក៏លើកជាទឡ្ហីករណ៍ផងដែរថា ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសម្ភារៈដោះបន្ទុកនេះ តែបែរសំអាងទៅលើការងាររបស់ ថេត សម្បត្តិ និង Robert LEMKIN សម្រាប់គោលបំណងដាក់បន្ទុកនោះ បានរំលោភដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[19]។

៩. ចំពោះសំណើដែលសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅ ថេត សម្បត្តិ និង Robert LEMKIN មកផ្តល់សក្ខីកម្មអំពីឈុតខ្សែវីដេអូ និងចាត់វិធានការភ្លាមៗដើម្បីទទួលយកឈុតខ្សែវីដេអូនេះ នួន ជា លើកឡើងថា អង្គជំនុំជម្រះមានអំណាចក្នុងការស្វែងរកភស្តុតាងថ្មី ទៅតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ហើយថា បញ្ញត្តិនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះ "ដើម្បីស្វែងរកភស្តុតាងបែបនេះ បើសិនខ្លួនយល់ថាសមស្រប"[20]។

១០. ក្នុងការឆ្លើយតបវិញ សហព្រះរាជអាជ្ញាលើកឡើងថា សំណើមានកំហុសនីតិវិធីដោយសារ នៅពេលដាក់សំណើ ពុំទាន់មានបណ្តឹងសាទុក្ខណាមួយត្រូវបានដាក់ប្រឆាំងទៅនឹងសាលក្រមសាលាដំបូងទេ ហើយថាពួកគេមិនអាចឆ្លើយតបឱ្យបានពេញលេញទៅនឹងសំណើទេរហូតទាល់តែវិសាលភាពរបស់បណ្តឹងសាទុក្ខត្រូវបានបង្ហាញ និងបញ្ហានានាដែលស្នើសុំឱ្យស្វែងរកភស្តុតាងពាក់ព័ន្ធ មានមូលដ្ឋានពេញលេញ[21]។

១១. ជាងនេះទៀត សហព្រះរាជអាជ្ញាលើកឡើងថា កិច្ចសម្ភាសន៍មិនអាចជឿទុកចិត្តបាន ដោយសារពឹងផ្អែក

---

[17] សំណើ កថាខណ្ឌ ១៤។

[18] សំណើ កថាខណ្ឌ ២ ដល់ ៤, ១៥។

[19] សំណើ កថាខណ្ឌ ៥។ សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣, ៥៧២។

[20] សារណាតប កថាខណ្ឌ ១៧។

[21] សារណាតប កថាខណ្ឌ ១ ដល់ ៥។

លើមតិផ្ទាល់ខ្លួនដែលគ្មានមូលដ្ឋាន ពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន ដែលបានលើកឡើងដោយបុគ្គលម្នាក់ដែលអះអាងថា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ នួន ជា[22]។ សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា សហផលិតករទាំងពីរនាក់មិនបានបង្ហាញការសហការណ៍ទេពីមុនមក ដោយអង្គជំនុំជម្រះសាលាដំបូងមិនអាចទាក់ទង ថេត សម្បត្តិ បាន[23]។ ពួកគេនៅតែរក្សាទស្សនៈថា ឈុតខ្សែវីដេអូដែលស្ថិតជាកម្មសិទ្ធិរបស់សហផលិតករមានសារៈសំខាន់ជាងសក្ខីកម្មរបស់ពួកគេ[24]។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា៖ (១) សក្ខីកម្មរបស់ ថេត សម្បត្តិ ត្រូវបានកំណត់ធ្វើក្នុងសំណុំរឿង ០០២/០២ នោះ អង្គជំនុំជម្រះតុលាការកំពូល "គួររង់ចាំមើលថាតើ [គាត់] យល់ព្រមមកបង្ហាញដែរ ឬយ៉ាងណា" នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"[25] ហើយថា (២) សក្ខីកម្មរបស់ Robert LEMKIN "គ្មានគុណតម្លៃទាល់តែសោះចំពោះអង្គជំនុំជម្រះនេះ" ដោយសារគាត់បានចូលរួមតិចតួចទៅក្នុងការស្រាវជ្រាវចម្បងរបស់ ថេត សម្បត្តិ[26]។

១២. ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖ (១) បដិសេធសំណើដោយចាត់ទុកថាវាឆាប់ពេក (២) ផ្តល់សេចក្តីណែនាំដល់ភាគីនានា អំពីពេលវេលាសមស្រប ក្នុងការដាក់សំណើសម្រាប់ភស្តុតាងបន្ថែម និង (៣) អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទាំងស្រុង បន្ទាប់ពីបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ត្រូវបានដាក់[27]។

## គ. ភាពអាចទទួលយកបាន

១៣. ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា សំណើមានកំហុសនីតិវិធី ដោយសារវាត្រូវបានដាក់ឆាប់ពេកនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ចាប់តាំងពីពេលដាក់សំណើ និងសារណាតប នួន ជា និង ខៀវ សំផន បានដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង សារណាលើបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមសាលាដំបូង។ ហេតុនេះ ការជំទាស់សហព្រះរាជអាជ្ញាទៅនឹងភាពអាចទទួលយកបាននៃសំណើថាឆាប់ពេក ជាការឥតប្រយោជន៍។ ប្រសិនបើសហព្រះរាជអាជ្ញានៅតែមានបំណងពន្យល់បន្ថែមទៀតចំពោះសារណាតបទៅនឹងសំណើនោះ ពួកគេអាចធ្វើបែបនេះបាននៅក្នុង

[22] សារណាតប កថាខណ្ឌ ៦, ១០ ដល់ ១១។

[23] សារណាតប កថាខណ្ឌ ៧ ដល់ ៨, ១៥។

[24] សារណាតប កថាខណ្ឌ ៦, ៩។

[25] សារណាតប កថាខណ្ឌ ១៥។

[26] សារណាតប កថាខណ្ឌ ១៦។

[27] សារណាតប កថាខណ្ឌ ២៥។

សារណារបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសារណាលើបណ្តឹងសាទុក្ខ។

## ឃ. ច្បាប់ជាធរមាន

១៤. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែង*ក្នុងចំណោមនោះ*ថា "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ"។ វិធាន ១០៤*ស្ទួន* ចែងថា "រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូលក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ"។

១៥. ពាក់ព័ន្ធនឹងញត្តិនានាដែលស្នើសុំដាក់ភស្តុតាងបន្ថែមទៅលើបណ្តឹងសាទុក្ខ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកពាក់ព័ន្ធថា៖

> ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការ ធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនង ដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសំអាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបាន លើក។

អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា វិធាននេះអនុវត្តចំពោះអង្គហេតុដែលទើបតែរកឃើញថ្មីៗផង និងមធ្យោបាយថ្មីៗនៃភស្តុតាងផង (*facta noviter producta* និង *facta noviter reperta*)។

១៦. ជាទូទៅ ការទទួលយកជាភស្តុតាងនៅចំពោះមុខ អ.វ.ត.ក ត្រូវបានគ្រប់គ្រងដោយវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ដែលភស្តុតាងទាំងអស់អាចទទួកយកបាន លុះត្រាតែមានការចែងផ្សេងពីនេះដោយវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង៖

> អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖
> ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា
> ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ។
> គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ។
> ឃ-ច្បាប់មិនអនុញ្ញាត ឬ
> ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

ហេតុនេះ វិធាននានាដែលគ្រប់គ្រងភាពទទួលយកបាននៃភស្តុតាង អនុវត្តចំពោះការពិចារណារបស់អង្គ

ជំនុំជម្រះតុលាការកំពូលចំពោះការស្វែងរក និងការគ្រប់គ្រងភស្តុតាងដែលនៅចំពោះមុខអង្គជំនុំជម្រះ។

១៧. អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ពីមាត្រា ២៩៨ និង មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥*ថ្មី*នៃច្បាប់ស្តីពី អ.វ.ត.ក និង មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ដែលបញ្ជាក់ពីសិទ្ធិក្នុងការការពារក្តី រួមទាំងវិធាននានាដែលត្រូវបានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិស្តីពីចំណុច ដែលត្រូវបានដកស្រង់នៅក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា[28]។

១៨. ដោយផ្អែកលើលក្ខណៈនៃភស្តុតាងដែលស្វែងរក ការពិចារណាទៅលើសំណើមួយចំនួនអាចតម្រូវឲ្យមានព័ត៌មានបន្ថែម និង ប្រសិនបើទទួលយកសំណើទាំងនោះ គេត្រូវបានពេលវេលាសមរម្យដើម្បីបង្ហាញភស្តុតាង។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ចំពោះពេលដែលសម្រេចលើភាពអាចទទួលយកបាននៃសំណើនានាសុំដាក់ភស្តុតាង និងថាតើគួរសម្រេចរួមគ្នា ឬដោយឡែកពីគ្នាចំពោះបញ្ហានានាដែលបានលើកឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[29]។ ការកំហិតនានាដែលថា ជាទូទៅភាគីត្រូវដាក់ពាក្យសុំដាក់ភស្តុតាងថ្មីមុនពេលបញ្ចប់សវនាការលើបណ្តឹងសាទុក្ខ[30] ហើយថា កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខត្រូវតែបញ្ចប់ក្នុងថិរវេលាដែលសមរម្យ[31]។

១៩. ជាងនេះទៀត អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដោយអានភ្ជាប់ជាមួយវិធាន ១០៤*ស្ទួន* អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចអនុវត្តកិច្ចស៊ើបសួរបន្ថែម ដើម្បីសម្រេចថា តើគួរ ឬមិនគួរ បើកសវនាការស្តាប់ភស្តុតាងបន្ថែម ឬ ភស្តុតាងផ្សេងៗទៀតលើបណ្តឹងសាទុក្ខ។

---

[28] *សូមមើល* សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨០។

[29] *សូមមើល* តុលាការព្រហ្មទណ្ឌអន្តរជាតិ *បទបញ្ជារបស់តុលាការ (Regulations of the Court)* (ត្រូវបានអនុម័តនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤) បទបញ្ជា ៦២(២)។ វិធាន ១១៥(គ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឯកសារ IT/32/Rev. 49 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ ("វិធានរបស់តុលាការICTY")។

[30] *សូមមើល* វិធាន ១០៩(៤) និង (៥) នៃវិធានផ្ទៃក្នុង និង វិធាន ៩៦(២) រួមគ្នាជាមួយវិធាន ១០៤*ស្ទួន*។ ប្រសិនបើមានញត្តិស្នើសុំដាក់ភស្តុតាងបន្ថែមបានកើតឡើងបន្ទាប់ពីសវនាការលើបណ្តឹងសាទុក្ខភាគី ដែលស្នើសុំគួរផ្តល់សំអាងហេតុច្បាស់លាស់ចំពោះការដាក់ញត្តិនៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។ *សូមមើល* វិធាន ១១៥(ក) នៃ វិធានរបស់តុលាការICTY។ តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង D. Milošević* សំណុំរឿងលេខ IT-98-29/1-A "សេចក្តីសម្រេចលើញត្តិទីបីរបស់ Dragomir Milošević ដែលស្នើសុំដាក់បង្ហាញភស្តុតាងបន្ថែម" ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ៦, ១៦ (ភាសាអង់គ្លេស)។

[31] វិធាន ១០៨(៤) នៃវិធានផ្ទៃក្នុង។

## ខ. ការពិភាក្សា

២០. ដូចបានលើកឡើងខាងលើ សំណើមានសំណូមពរពីរដាច់ពីគ្នា ពោលគឺ (១) ថា អង្គជំនុំជម្រះតុលាការកំពូលគួរទទួលយកកិច្ចសម្ភាសន៍ជាភស្តុតាង និង (២) ថា អង្គជំនុំជម្រះគួរកោះហៅ ថេត សម្បត្តិ និង Robert LEMKIN និង ទទួលយកឈុតខ្សែវីដេអូ។ សំណូមពរទីមួយ សំដៅដល់សំណើតាមវិធាន ១០៨ (៧) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកភស្តុតាងបន្ថែម។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កិច្ចសម្ភាសន៍មានជាសាធារណៈទៅហើយ ហើយថា ពុំមានការលំបាកក្នុងការទទួលយកជាភស្តុតាងទេ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចទទួលយកនោះ។ ថ្វីត្បិតតែយ៉ាងនេះក្តី ដោយសារដំណាក់កាលបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ និងដោយសារថា សំណើផ្សេងៗទៀតសុំឱ្យទទួលយកភស្តុតាង កំពុងស្ថិតក្នុងការសម្រេចរបស់អង្គជំនុំជម្រះនោះ អង្គជំនុំជម្រះយល់ថា វាមិនមែនជាការសមរម្យដែលត្រូវសម្រេចលើភាពអាចទទួលយកបាននៃកិច្ចសម្ភាសន៍នៅពេលនេះទេ។ ហេតុនេះ សេចក្តីសម្រេចលើចំណុចនេះនៃសំណើ នឹងធ្វើឡើងនៅពេលក្រោយ។

២១. ចំពោះសំណូមពរទីពីរ ដូចបានរម្លឹកឡើងខាងលើរួចមកហើយ នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តី នួន ជា បានទទួលសារអេឡិចត្រូនិកមួយច្បាប់ពី Robert LEMKIN ដែលចង្អុលបង្ហាញ*ក្នុងចំណោមនោះ*ថា "ទាក់ទិននឹងទួលពោធិ៍ជ្រៃ គឺជាកន្លែងសម្លាប់រង្គាល ក្រោមបញ្ជារបស់ រស់ ញឹម ពុំមែនក្រោមបញ្ជារបស់មជ្ឈិមបក្សឡើយ" ហើយថា គាត់ និង ថេត សម្បត្តិ បាន "ប្រមូលភស្តុតាងជាច្រើនអំពីផែនការរបស់ ញឹម"[32]។ នួន ជា បានស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងគួរទទួលយកសារអេឡិចត្រូនិកនេះជាភស្តុតាង កោះហៅ Robert LEMKIN មកផ្តល់សក្ខីកម្ម និងផ្តួចផ្តើមបើកកិច្ចស៊ើបសួរប្រមូលសម្ភារៈដែលទាក់ទិននឹងតួនាទីរបស់ រស់ ញឹម នៅទួលពោធិ៍ជ្រៃ ដើម្បីអាចបញ្ចូលសម្ភារៈទាំងនោះជាភស្តុតាងបាន[33]។

២២. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ជាសេចក្តីសម្រេចមួយដែល នួន ជា អះអាងជាផ្នែកខ្លះនៃមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់ខ្លួនថា "ការខកខានរបស់អង្គជំនុំជម្រះ[សាលាដំបូង]មិនបានព្យាយាមទទួលយកភស្តុតាង [បែបនេះ]" គឺជា

[32] សំណើសុំទទួលយកជាភស្តុតាងថ្មី កោះហៅ Rob LEMKIN ចាប់ផ្តើមការស៊ើបអង្កេត ឯកសារ E294 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ("សំណើសុំកោះហៅ និង បើកកិច្ចស៊ើបសួរ") កថាខណ្ឌ ២។

[33] សំណើសុំកោះហៅ និង បើកកិច្ចស៊ើបសួរ កថាខណ្ឌ ១១ ដល់ ១៥។ ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះក្តី (ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣) ឯកសារ E1/221.1 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១០ (បន្ទាត់ ៥ ដល់ ១៧) (ភាសាអង់គ្លេស)។

01082154



កំហុសលើអង្គច្បាប់ដែលបាននាំឱ្យមានការរំលោភបំពានដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[34]។ អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយនូវទឡ្ហីករណ៍ទាំងនោះ នៅពេលពិចារណាទៅលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខ។ ថ្វីត្បិតតែយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលជាប់កាតព្វកិច្ចត្រូវផ្តល់សេចក្តីសង្កេតថា ទោះបីអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា សម្ភារៈមានភាពពាក់ព័ន្ធ*តាមការវិភាគបឋម*[35] តែអង្គជំនុំជម្រះបានបដិសេធមិនបើកកិច្ចស៊ើបសួរទៅក្នុងខ្លឹមសារជាក់លាក់ និងភាពដែលអាចរកបានរបស់វា ដោយផ្អែកលើការព្រួយបារម្ភអំពីការចេញសាលក្រមឱ្យបានទាន់ពេលវេលា និងការព្រួយបារម្ភថា កិច្ចស៊ើបសួរនឹងមិនអាចបញ្ចប់ក្នុងអំឡុងពេលសមរម្យបានទេ[36]។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ថា ខ្លួនមិនអាចយល់ស្របតាមការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីត្រូវតែមានតុល្យភាពទៅលើលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្តីឆាប់រហ័ស នោះទេ[37]។ អង្គជំនុំជម្រះនៅ អ.វ.ត.ក មានកាតព្វកិច្ចត្រូវធានាថា កិច្ចដំណើរការនីតិវិធីត្រូវមានភាពត្រឹមត្រូវយុត្តិធម៌ផង និងឆាប់រហ័សផង[38]។ នៅទីនេះ ទិដ្ឋភាពទាំងពីរនៃការជំនុំជម្រះក្តីដោយយុត្តិធម៌មានភាពពាក់ព័ន្ធៈ សិទ្ធិរបស់ជនជាប់ចោទដែលទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលឥតប្រយោជន៍[39] និងសិទ្ធិ "ទទួលបានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន"[40]។ ពាក់ព័ន្ធនឹងទិដ្ឋភាពទីមួយ តម្លៃជាភស្តុតាងនៃភស្តុតាងដែលភាគីបានស្នើឡើង*ក្នុងការគាំទ្រ*ដល់បទចោទអាចត្រូវមានតុល្យភាពទៅនឹងពេលវេលាដែលតម្រូវក្នុងការទទួលបានភស្តុតាងនោះ ដែលវាអាចនឹងអន្តរាយដល់សិទ្ធិ

[34] សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧២។ *សូមមើលផងដែរ* សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣។

[35] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦។

[36] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤។

[37] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩។

[38] មាត្រា ៣៣*ថ្មី*នៃច្បាប់ អ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស [...]"។ *សូមមើលផងដែរ* មាត្រា ៦៤(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រា ២០(១) នៃលក្ខន្តិកៈតុលាការ ICTR តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សំណុំរឿងលេខ IT-95-14/1-AR73 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាស្តីពីភាពអាចទទួលយកបាននៃភស្តុតាង" ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩ (ភាសាអង់គ្លេស)។

[39] មាត្រា ១៤(៣)(គ) នៃ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[40] មាត្រា ១៤(៣)(ង) នៃ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

របស់ជនជាប់ចោទ ដែលត្រូវទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យាពេលឥតប្រយោជន៍[41]។ ទោះជាយ៉ាងណា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលឥតប្រយោជន៍មិនបានកំហិតសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភស្តុតាង ក្នុងនាមខ្លួនទេ។ ផ្ទុយទៅវិញ ការព្រួយបារម្ភជាទូទៅពីភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី បានប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភស្តុតាងដែលញត្តិស្នើសុំបង្ហាញភស្តុតាង នឹងមិនជួយដល់ការការពារក្តី *តាមព្រឹត្តិហេតុ* (*de facto*) ទេ ដូចដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលថា ភស្តុតាងអាចនឹងត្រូវបានបដិសេធ ប្រសិនបើវាមិនពាក់ព័ន្ធ ច្រំដែលៗ ឬញត្តិស្នើសុំនោះមានគោលបំណងអូសបន្លាយកិច្ចដំណើរការនីតិវិធី[42]។ ទោះជាយ៉ាងណា ការសម្រេចបែបនេះមិនមានក្នុងសេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ទេ។

២៣. ពាក់ព័ន្ធនឹងសំណើដែលកំពុងរង់ចាំការសម្រេច អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដោយផ្អែកលើព័ត៌មានដែលមានក្នុងកំណត់ហេតុ ឈុតខ្សែវីដេអូរួមមានជាចម្បងគឺ កិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ ជាមួយ នួន ជា ចំណែកឯផ្នែកមួយទៀត រួមមានកិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ ជាមួយបុគ្គលផ្សេងទៀត ដែលពួកគេភាគច្រើនជាអតីតសមាជិកខ្មែរក្រហម។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ត្រូវបានធ្វើឡើងមុនពេលមានការចាប់ខ្លួន នួន ជា នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ហើយមិនអាចមានវិមតិសង្ស័យពីការដឹងរបស់គាត់ និងសហមេធាវីរបស់គាត់អំពីអត្ថិភាពនៃសម្ភារៈនេះទេ។ សហមេធាវីការពារបានទាក់ទងដោយផ្ទាល់ជាមួយ ថេត សម្បត្តិ[43] ហើយបានដឹងពីការព្រមព្រៀងរបស់ នួន ជា ក្នុងការរក្សា

---

[41] *សូមមើល* ឧទាហរណ៍ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង A. Gotovina និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-06-90-AR73.6 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់ Ivan Čermak និង Mladen Markač ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបើករឿងក្តីរបស់អយ្យការឡើងវិញ" ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៣ ដល់ ២៤ (ភាសាអង់គ្លេស)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Z. Delalic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A "សាលក្រម" ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៩០ (ភាសាអង់គ្លេស)។ ជាទូទៅ ទៅលើតម្រូវឲ្យរក្សានូវភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចសំណើរការនីតិវិធី នៅពេលសម្រេចលើសំណើសុំដាក់ភស្តុតាងសម្រាប់ចោទប្រកាន់ *សូមមើល* ឧទាហរណ៍ តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង M. Milutinovic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-AR73.1 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីលើកទីពីរ ដែលបានបដិសេធអយ្យការមិនឲ្យបន្ថែមលោកឧត្តមសេនីយ៍ Wesley Clark ទៅក្នុងបញ្ជីឈ្មោះសាក្សីចំនួន ៦៥ នាក់របស់ខ្លួន" ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ១៧ ដល់ ២០ (ភាសាអង់គ្លេស)។

[42] *សូមមើល* ផងដែរ តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង II *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង J. Kanyabashi* សំណុំរឿងលេខ ICTR-96-15-T "សេចក្តីសម្រេចលើញត្តិរបស់ Kanyabashi ដែលស្នើសុំបើករឿងក្តីរបស់ខ្លួនឡើងវិញ និងសុំកោះហៅដើម្បីសួរឆ្លើយសាក្សីរបស់អយ្យការឡើងវិញ" ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ២៣ *និងកថាខណ្ឌបន្តបន្ទាប់* (ភាសាអង់គ្លេស)។

[43] *សូមមើល* សារណាតបទីមួយ កថាខណ្ឌ ១០ (ដែលពិពណ៌នាអំពីរបៀបដែលក្រុមមេធាវីការពារក្តី នួន ជា ជួយ ថេត សម្បត្តិ ក្នុងការចូលទៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ដោយលួចលាក់)។

ការសម្លាប់ជាមួយ Robert LEMKIN "ចាប់តាំងពីយ៉ាងហោចណាស់ក៏ក្នុងខែ មិថុនា ឆ្នាំ ២០១១ ដែរ"[44]។ ប្រសិនបើ នួន ជា មានចេតនាប្រើប្រាស់កិច្ចសម្ភាសន៍របស់គាត់ជាមួយ ថេត សម្បត្តិ មែន គាត់មានឱកាសជាច្រើនក្នុងការធ្វើបែបនេះ តាំងពីដំណាក់កាលដំបូងៗនៃការជំនុំជម្រះក្តីម្ល៉េះ។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើ ដែលត្រូវបានបកស្រាយឲ្យបានសមរម្យនោះ យោងទៅដល់ឈុតខ្សែវីដេអូដែលនៅសល់ប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងឈុតខ្សែវីដេអូនេះ នួន ជា ប្រកាសថា គាត់បានដឹងពីអត្ថិភាពនៃសម្ភារៈដោះបន្ទុក បន្ទាប់ពីបានទទួលសារអេឡិចត្រូនិច "គ្មានការស្នើសុំពីភាគី" របស់ Robert LEMKIN នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ ប៉ុណ្ណោះ[45]។ ហេតុនេះ ពុំមានការចង្អុលបង្ហាញក្នុងកំណត់ហេតុថា សំណើសុំផ្តួចផ្តើមកិច្ចស៊ើបសួរគួរតែត្រូវបានចាត់ទុកថាយឺតយ៉ាវទេ។

២៤. អង្គជំនុំជម្រះតុលាការកំពូលរម្លឹកថា ជាលទ្ធផលនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ពុំមានព័ត៌មានស្តីពីរបាយការណ៍ទាក់ទងនឹងបញ្ហាថាតើ ឈុតខ្សែវីដេអូ អាចទទួលបាន ដែរ ឬយ៉ាងណា ហើយថាតើ វាពិតជាពាក់ព័ន្ធនឹងបញ្ហានានាដែលបានលើកឡើងក្នុងរឿងក្តីនេះ ដែរ ឬយ៉ាងណា។ ហេតុនេះ ដើម្បីចេញសេចក្តីសម្រេចចាំបាច់ស្តីពីភាពពាក់ព័ន្ធ និងភាពអាចរកបាននៃឈុតខ្សែវីដេអូបាន អង្គជំនុំជម្រះតុលាការកំពូលយល់ថាជាការសមរម្យដែលត្រូវប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដែលអាចជាមួយវិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង និងបើកកិច្ចស៊ើបសួរបន្ថែមតូចមួយ។ គោលបំណងនៃកិច្ចស៊ើបសួរនេះគឺជាចម្បងដើម្បីស្វែងរកឲ្យឃើញថាតើ ឈុតខ្សែវីដេអូ ដែលមិននិយាយពីកិច្ចសម្ភាសន៍របស់ នួន ជា ជាមួយ ថេត សម្បត្តិ អាចអាចទទួលបានក្នុងអំឡុងពេលវេលាសមស្រប ដែរ ឬយ៉ាងណា ហើយថាតើ មានព័ត៌មានជាក់លាក់អ្វីខ្លះ ដែលអាចដកស្រង់ពីកិច្ចសម្ភាសន៍នោះបាន។

២៥. ការដែរថាតើ ឈុតខ្សែវីដេអូនេះ អាចទទួលបានទាន់ពេលវេលា ដែរ ឬយ៉ាងណានោះ អាស្រ័យលើកត្តាមួយចំនួន។ ចំណុចសំខាន់ គឺឆន្ទៈរបស់សហផលិតករក្នុងការផ្តល់សម្ភារៈដែលមានក្នុងកម្មសិទ្ធិរបស់ខ្លួនទៅឲ្យតុលាការ។ អង្គជំនុំជម្រះ កត់សម្គាល់ពីប្រវត្តិនៃការមិនបានត្រៀមខ្លួនរបស់ ថេត សម្បត្តិ និង Robert LEMKIN ក្នុងការសហការណ៍ជាមួយតុលាការ ដែលទំនងជាមូលហេតុសំខាន់ដែលឈុតខ្សែវីដេអូនៅតែមិនទាន់បានបញ្ចូលក្នុងសំណុំរឿង ហើយអាចជាការឥតប្រយោជន៍ដូចគ្នា ដែលប៉ុនប៉ងទទួលយកវាជាកម្មសិទ្ធិ។ ទោះជាយ៉ាង អង្គជំនុំជម្រះ កត់សម្គាល់ថា អស់រយៈពេលជាងបួនឆ្នាំមកហើយ ចាប់

---

[44] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២២។

[45] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣) ឯកសារ E1/221.1 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៧ (បន្ទាត់ ៨ ដល់ ១៦) (ភាសាអង់គ្លេស)។

តាំងពីពេលដែលតុលាការបានព្យាយាមចុងក្រោយក្នុងការទាក់ទងជាមួយសហផលិតករ[46] ដែលកាលៈទេសៈនានាអាចនឹងមានការប្រែប្រួល។ បញ្ហានេះនឹងត្រូវសម្រេចដោយស្វែងរកការទាក់ទងដោយផ្ទាល់ជាមួយសហផលិតករ។ ដើម្បីពន្លឿនកិច្ចស៊ើបសួរ អង្គជំនុំជម្រះតុលាការកំពូលសម្រាប់ចាត់តាំងចៅក្រមតំណាងពីររូប (“ចៅក្រមតំណាង”) ដែលត្រូវបើកកិច្ចស៊ើបសួរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។ ចៅក្រមតំណាងអាចស្តាប់ចម្លើយសាក្សី ដោយពុំមានវត្តមានភាគី និងក្នុងករណីចាំបាច់ តាមមធ្យោបាយបច្ចេកវិទ្យាសោតទស្សន៍[47]។ ចៅក្រមតំណាង ត្រូវផ្តល់ព័ត៌មានដល់ភាគីពីស្ថានភាពនៃកិច្ចស៊ើបសួរ ដោយផ្តល់លទ្ធភាពសមរម្យដល់ពួកគេក្នុងការធ្វើជាតំណាងក្នុងកិច្ចស៊ើបសួរនោះ។ ដោយផ្អែកលើព័ត៌មានដែលទទួលបានតាមរយៈកិច្ចស៊ើបសួរបន្ថែមនេះ ចៅក្រមតំណាង ឬ អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសេចក្តីសម្រេចមួយពីរបៀបដំណើរការលើបញ្ហានេះបន្តទៅមុខទៀត។

## ច. ផ្នែកសម្រេចសេចក្តី

២៦. ដោយសារមានសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច÷**

**ទទួលយក** ផ្នែកខ្លះនៃសំណើ។

**សម្រេច** ផ្តួចផ្តើមកិច្ចស៊ើបសួរបន្ថែម ក្នុងគោលបំណងបង្ហាញថាតើ ឈុតខ្សែវីដេអូ អាចត្រូវបានទទួលយកក្នុងអំឡុងពេលសមស្រប ដែរ ឬយ៉ាងណា ហើយប្រសិនសមស្រប អង្គជំនុំជម្រះនឹងទទួលយកឈុតខ្សែវីដេអូនេះ។

**ចាត់តាំង** ចៅក្រម **ម៉ុង មុន្នីចរិយា** និង ចៅក្រម Chandra Nihal JAYASINGHE ជាចៅក្រមតំណាងក្នុងការបើកកិច្ចស៊ើបសួរ ក្នុងនាមអង្គជំនុំជម្រះ។

**ណែនាំ** អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ប្រើប្រាស់អស់សមត្ថភាពរបស់ខ្លួន ដើម្បីទាក់ទង ថេត សម្បត្តិ និង **Robert LEMKIN** និងរាយការណ៍ពីលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់ខ្លួន ជូនដល់ចៅក្រមតំណាងត្រឹមថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥។

---

[46] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ជើងទំព័រ ៣១។ *សូមមើលផងដែរ* អនុស្សរណៈអន្តរការិយាល័យ៖ សាក្សីសក្តានុពល - ដែលមិនអាចរកបាន ឯកសារ E292/1/2 ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៣ (ដែលលេចឡើងថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“WESU”) មិនអាចទទួលបានព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងជាមួយ ថេទ សម្បត្តិ នៅត្រឹមថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៣)។

[47] វិធាន ២៦, ៥៥(៧) និង ៦០(២) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* វិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៥៣។

ស្នើឲ្យភាគីជួយដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការផ្តល់ព័ត៌មានសម្រាប់ទំនាក់ទំនង ថេត សម្បត្តិ និង Robert LEMKIN ដែលភាគីគេអាចដឹង។

**រក្សាទុកទទួលយកមកពិនិត្យ** នូវផ្នែកដែលនៅសេសសល់នៃសំណើនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**